ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ
# រយៈពេល ៣ ឆ្នាំ
# (២០០៨-២០១០)

ឈ្មោះសហគមន៍នេសាទ : ភូមិថ្មី
ភូមិ : ថ្មី
ឃុំ : កំពង់អុស
ស្រុក : ជលគីរី
ខេត្ត : កំពង់ឆ្នាំង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ

## រយៈពេល ៣ ឆ្នាំ

## (២០០៨-២០១០)

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | : | ភូមិថ្មី |
| ភូមិ | : | ថ្មី |
| ឃុំ | : | កំពង់អុស |
| ស្រុក | : | ជលគីរី |
| ខេត្ត | : | កំពង់ឆ្នាំង |

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទ ភូមិថ្មី ត្រូវបានបង្កើតឡើង ដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី **១៩** ខែ **មិថុនា** ឆ្នាំ **២០០៧** និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី **១១** ខែ **មករា** ឆ្នាំ **២០០៨**។

សហគមន៍នេសាទ **ថ្មី** មានទីតាំងស្ថិតនៅក្នុង ភូមិ **ថ្មី** ឃុំ **កំពង់អុស** ស្រុក **ជលគីរី** ខេត្ត **កំពង់ឆ្នាំង** ដែលមានសមាជិកសរុបចំនួន **១៨២** នាក់ ស្រីចំនួន **៩៥** នាក់ និងមានគណៈកម្មការចំនួន **៧** នាក់ ស្រីចំនួន **គ្មាន**។ ក្នុងនោះចំនួនគ្រួសារសរុប មានចំនួន **៧៣** គ្រួសារ ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមាន៖ ចូលរួមវគ្គបណ្តុះបណ្តាល ចុះបញ្ជីសមាជិក ធ្វើមហាសន្និបាត ធ្វើលក្ខន្តិកៈ ធ្វើបទបញ្ជាផ្ទៃ ដាក់បំរាមហាមឃាត់ការកាប់បំផ្លាញព្រៃលិចទឹក បង្ក្រាបបទល្មើសឆក់ត្រីនៅក្នុងសហគមន៍។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក -ប្រជាពលរដ្ឋ៖

- ចំនួនប្រជាពលរដ្ឋក្នុងភូមិសរុបក្នុងសហគមន៍នេសាទមាន **៤៣៨** នាក់ប្រុស **១៩៣** នាក់ ស្រី **២៤៥** នាក់ ក្នុងនោះមានជនជាតិខ្មែរចំនួន **៤៣៨** នាក់ ។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ១៤ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ៥ នាក់ស្រី ២ នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ១៧ នាក់ ស្រី ១១ នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន គ្មាន ស្រី គ្មាន
- ចំនួនអ្នកមានជំងឺរាំរ៉ៃក្នុងសហគមន៍នេសាទមាន ៦ នាក់ ស្រី ៦ នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ **១០០%**
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន ៨ នាក់ ស្រី **៦** នាក់ ក៏រិតថ្នាក់បឋមសិក្សាចំនួន **១៧០** នាក់ ស្រី **៧៤** នាក់ ។

### ខ -មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន៖

- ធ្វើនេសាទចំនួន ៧៣ គ្រួសារ
- ធ្វើស្រែចំនួន ៥០ គ្រួសារ

- ធ្វើវារីវប្បកម្មចំនួន ២ គ្រួសារ ទំហំ ១២០០ ម$^{២}$
- ដាំបន្លែចំនួន ៣ គ្រួសារ ទំហំ ២០០០០ ម$^{២}$
- ជាងផ្ទះចំនួន ៤ គ្រួសារ
- ធ្វើចំការចំនួន ៧៣ គ្រួសារ
- លក់ដូរ ចំនួន ២ គ្រួសារ
- កែច្នៃផលនេសាទ ១០ គ្រួសារ
- ជាងទូក ចំនួន ៥ គ្រួសារ
- បិទស្រា ចំនួន ១ គ្រួសារ
- កិនស្រូវ ចំនួន ៤ គ្រួសារ

## ៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក. ទីតាំង

កន្លែងនេសាទសហគមន៍ **ភូមិថ្មី** ជាកន្លែងដែលត្រូវបានកាត់ចេញពីឡូត៍នេសាទ លេខ **១៣**

ដែននេសាទទឹក

សាប ។

កន្លែងនេសាទសហគមន៍ **ភូមិថ្មី** មានទំហំ **១៣៧៥** ហិកតា និងមានកំណត់និយាមកា

ដូចមានចែងនៅក្នុងកិច្ចព្រម ព្រៀង ។

មានព្រំប្រទល់ :

- ខាងជើងទល់នឹង **ទន្លេច្រឡៃ ( ព្រំប្រទល់ឡូត៍លេខ ១២)**
- ខាងត្បូងទល់នឹង **សហគមន៍ភ្នង**
- ខាងកើតទល់នឹង **ទន្លេភ្នង**
- ខាងលិចទល់នឹង **សហគមន៍គៀនតាម៉ា**

### ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍ ភូមិថ្មី មានបឹងចំនួន **៦** ព្រែកចំនួន **២** ត្រពាំងចំនួន **គ្មាន** ស្រះចំនួន **គ្មាន** និងមេទឹកចំនួន **គ្មាន** ។

- បឹង **ព្រលិត** ទំហំ ២ ហិកតា នេសាទពីខែ ធ្នូ ដល់ខែ មិថុនា
- បឹង **កក់** ទំហំ ០.៥ ហិកតា នេសាទពីខែ ធ្នូ ដល់ខែ មិថុនា
- បឹង **ថាស** ទំហំ ០.៥ ហិកតា នេសាទពីខែ ធ្នូ ដល់ខែ មិថុនា
- បឹង **អាយូ** ទំហំ ១ ហិកតា នេសាទពីខែ ធ្នូ ដល់ខែ មិថុនា
- បឹង **វាល** ទំហំ ១០ ហិកតា នេសាទពីខែ ធ្នូ ដល់ខែ មិថុនា

- បឹង **ពោ** ទំហំ ១ ហិកតា នេសាទពីខែ ធ្នូ ដល់ខែ មិថុនា
- ព្រែក **ស្ពានថ្មីទី១** ប្រវែង ២០០ ម ទទឹង ៧ ម គ្មាននេសាទ
- ព្រែក **ស្ពានថ្មីទី២** ប្រវែង ២០០ ម ទទឹង ៧ ម គ្មាននេសាទ

**ឥ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

សហគមន៍គ្មានកន្លែងសមស្របដើម្បីធ្វើកន្លែងអភិរក្សទេ។

**ឃ. ធនធានជលផល**

- ប្រភេទត្រី :
    - ➢ ប្រភេទត្រីដែលមានការកើនឡើង : កញ្ចុះ ក្រុសខ្នងវែង ក្រុសមេម៉ាយ ច្រកែង។
    - ➢ ប្រភេទត្រីដែលមិនថយ និងមិនកើនឡើង : ត្រីរ៉ស ត្រីអណ្តែង ត្រីឆ្លាត ឆ្តោ ត្រីរៀល ត្រីឆ្កោក ក្លាំងហាយ គ្រុំ ក្រឡង់ ច្រឡឹង។
    - ➢ ប្រភេទត្រីដែលមានការថយចុះ : ត្រីក្រពាត់ សណ្តាយ ស្លឹកឫស្សី កញ្ចូនជ័យ ឆ្តិន គល់រាំង កន្ធរ ក្អែក និងត្រីដំរី ។
- ប្រភេទវារីសត្វ : ក្តាម កំពិស ពស់ អន្ទង់ ខ្យង និងខ្ចៅ។
- ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ : រាំង ត្រស់ ទ្រាល ខ្នាយមាន់ អាញ្ចៀ ថ្លើមអណ្តើក បបួយ អញ្ចាញ បន្ទាយូន បន្ទាស្អិត ស្វាព្រាម វល្លិធ្មេញត្រី វល្លិប្រេង វល្លិសន្ទែ វល្លិតាអើក វល្លិសាវម៉ាវព្រៃ ត្រកួន កន្ទាំងហែរ ជីប៉ូង កំប្លោក ចក។

**៤. ការធ្វើនេសាទ**

**ក. អ្នកនេសាទ**

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ១៨៦ នាក់ ស្រី ៨៦ នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍មានចំនួន ៦៦៨ នាក់ ស្រី ៣៦៨ នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន ៣០ នាក់ ស្រី ១០ នាក់

**ខ. ឧបករណ៍នេសាទ**

- ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ:

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|
| មង | ១ដៃ=៥០ម | ១ដៃ×២៤០នាក់= | ចំនួន=១២០០០ ម<br>ក្រឡា=២,៥-៤,៥សម | ខែមករា ដល់ ខែធ្នូ |

| | | | | |
|---|---|---|---|---|
| | | | ជំរៅ=១.២ម | |
| លាន់អន្លង់ | គ្រឿង | ៨០គ្រឿង×១០នាក់= | ចំនួន=៨០០ គ្រឿង | ខែមិថុនា ដល់ ខែធ្នូ |
| សន្ទូចរនង | ផ្លែ | ៦០ផ្លែ×៤០នាក់= | ចំនួន=២៤០០ផ្លែលេខ១៤ | ខែសីហា ដល់ ខែមេសា |
| លបក្លាំងហាយ | គ្រឿង | ៥គ្រឿង×១០នាក់= | ចំនួន=៥០ គ្រឿង<br>ក្រឡាត្រៀម= ៣សម<br>កំពស់=១.២ ,<br>មុខកាត់=0.៦ម | ខែមិថុនា ដល់ ខែធ្នូ |
| សំណាញ់ | វង់ | ១វង់×១០នាក់= | ១០ គ្រឿង | ខែមករា ដល់ ខែធ្នូ |
| ទ្រូ | គ្រឿង | ៥គ្រឿង×១៥នាក់= | ៧៥ គ្រឿង | ខែសីហា ដល់ ខែកញ្ញា |
| លបត្រីរស់ | គ្រឿង | ៥គ្រឿង×២០នាក់= | ចំនួន=១០០គ្រឿង<br>ក្រឡាត្រៀម= ៣សម<br>កំពស់=១.២ ,<br>មុខកាត់=0.៦ម | ខែសីហា ដល់ ខែធ្នូ |
| លបកំពឹស | គ្រឿង | ៥គ្រឿង×២៥នាក់= | ចំនួន=១២៥ គ្រឿង<br>ក្រឡាត្រៀម= ៣សម<br>កំពស់=១.២ ,<br>មុខកាត់=0.៦ម | ខែសីហា ដល់ ខែធ្នូ |
| លបត្រីដីរ៍ | គ្រឿង | ២គ្រឿង×១០នាក់= | ចំនួន=២០ គ្រឿង<br>ក្រឡាត្រៀម= ៣សម<br>កំពស់=១.២ ,<br>មុខកាត់=0.៦ម | ខែមិថុនា ដល់ ខែកញ្ញា |

| **ប្រភេទទូក កាណូត** | **ចំនួន** | **ចំណុះ** | **កំលាំងសេះ** |
|---|---|---|---|
| កាណូត | ២គ្រឿង | ៥០០០ គក្រ | ម៉ាស៊ីនរថយន្ត |
| កាណូត | ២គ្រឿង | ៥០០០ គក្រ | ១៨ សេះ |
| កាណូត | ១៧២គ្រឿង | ១០០-១៥០ គក្រ | ៨-១០ សេះ |
| ទូកក្តោត | ៨គ្រឿង | ៧០-១០០ គក្រ | |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ៖

| **ប្រភេទឧបករណ៍** | **ឯកតា** | **ចំនួន** | **ទំហំ/ប្រវែង** |
|---|---|---|---|
| មង | ១ដៃ=១០០ម | ១ដៃ×៣០នាក់= | ចំនួន=៣០០០ម<br>ក្រឡា=២,៥-៤,៥សម<br>ជំរៅ=១,២ម |
| លបកំពឹស | គ្រឿង | ៣០គ្រឿង×១០នាក់= | ចំនួន=៣០០ គ្រឿង |
| សន្ទូចរនង | ផ្លែ | ១០០ផ្លែ×២០នាក់= | ២០០០ ផ្លែលេខ១៤ |

| **ប្រភេទទូក កាណូត** | **ចំនួន** | **ចំណុះ** | **កំលាំងសេះ** |
|---|---|---|---|
| កាណូត | ១០០ | ១០០-១៥០ គក្រ | ៨-១០ សេះ |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ៖

| **ប្រភេទឧបករណ៍** | **ឯកតា** | **ចំនួន** | **ទំហំ/ប្រវែង** |
|---|---|---|---|
| មង | ១ដៃ=៥០ម | ១ដៃ×៣០នាក់= | ១៥០០ ម |
| លាន់អន្លង់ | គ្រឿង | ៤០គ្រឿង×៦០នាក់= | ២៤០០ គ្រឿង |
| សន្ទូចរនង | ផ្លែ | ១០០ផ្លែ×៣០នាក់= | ៣០០០ ផ្លែ |

## គ. ប៉ាន់ប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ *(គិតជា គក)* | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៨០០ គក្រ | ៤០០០ គក្រ | ៤៨០០ គក្រ |
| ក្ដាម ខ្យង | ១០០ គក្រ | ៥០ គក្រ | ១៥០ គក្រ |
| ល្មៀស | ៥០ គក្រ | ២០ គក្រ | ៧០គក្រ |

# ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

## ក. ទស្សនៈវិស័យ

សហគមន៍នេសាទ **ភូមិថ្មី** មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយ សមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

## ៩. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុប ឬកាត់បន្ថយពីនាទីឡូត៍នេសាទ កន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង ទំនាបលិចទឹកក្នុងរដូវជំនើង នាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធាន ជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទ តាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការ ចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

## គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ.១- ផែនការប្រើប្រាស់ឧបករណ៍នេសាទៈ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទ ដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោមៈ

| ឈ្មោះ/ទីតាំង កន្លែងនេសាទ | ពេលវេលា ធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | |
|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន |
| បឹងព្រលិត | នេសាទពីខែ ធ្នូ ដល់ខែ មិថុនា | មង | ចំនួន=១៨៥០០ ម<br>ក្រឡា=២,៥-៥,៥សម<br>ជំរៅ=១,៥ម | ៣៧០នាក់/១នាក់<br>អនុញ្ញាតឱ្យ៥០ម |
| បឹងកក់ | នេសាទពីខែ ធ្នូ ដល់ខែ មិថុនា | លាន់អន្ទង់ | ចំនួន=៣២០០គ្រឿង | ៨០នាក់/នាក់<br>៤០គ្រឿង |
| បឹងអាយូ | នេសាទពីខែ សីហា ដល់ខែ ធ្នូ | សន្ទូចរនង<br><br>លបក្លាំងហាយ | ចំនួន=១០០០០ផ្លែ<br><br>ចំនួន=២០ គ្រឿង<br>ក្រឡាគ្រៀម= ៣សម<br>កំពស់=១.២ | ១០០នាក់/១០០ផ្លែ<br><br>១០នាក់/១នាក់ប្រើ<br>២គ្រឿង |

| | | | | |
|---|---|---|---|---|
| | | | មុខកាត់=០.៦ម | |
| បឹងវាល | | សន្ទូចរនង<br>លបត្រីដីរ | ចំនួន=៨០០០ផ្លែ<br>ចំនួន=១០ គ្រឿង<br>ក្រឡាត្រៀម= ៣សម<br>កំពស់=១.២<br>មុខកាត់=០.៦ម | ១០០នាក់/៨០ផ្លែ<br><br>១០នាក់/១នាក់ប្រើ<br>១គ្រឿង |

## គ.២ ផែនការកែលំអដែននេសាទ

ផែនការកែលំអដែននេសាទត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ (គ្មាន)

| ឈ្មោះដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងកន្លែងវាល | ១០ហ.ត | ១០០ម x១០០ម<br>ជំរៅ=១ម | ស្តារបឹង | មិនា ២០០៩ | ឧសភា ២០១០ | |

## គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស នឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ (គ្មាន)

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទ នៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងវាល | ១០០ម<br>x១០០ម | បឹងអភិរក្ស | ប្រជុំផ្សព្វផ្សាយ<br>បោះបង្គោល<br>ស្លាក រុំខ្សែលួស<br>ដាក់លូ | ឧសភា ២០០៩ | សីហា ២០១០ | |

## គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើ ដែលត្រូវដាំ និងការពារ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១-ដាំព្រៃលិចទឹក<br>បឹងកន្លែងវាល | ២ ហិកតា | រាំង ត្រស់ | ប្រជុំផ្សព្វផ្សាយ<br>ធ្វើថ្នាលបណ្តុះ<br>កូនរាំង ត្រស់ | មិនា២០០៩ | ឧសភា២០១០ | |

| | | | | | | |
|---|---|---|---|---|---|---|
| ២-ថែរក្សា និង រំលោះព្រៃលិចទឹក | ថែរក្សា | ថែរក្សា | ថែរក្សា | | | |

## គ.៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

- ផែនការអភិវឌ្ឍន៍វារីវប្បកម្មត្រូវបានរៀបចំឡើងដូចខាងក្រោមៈ

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| ស្រះ | ២ | អណ្តែង | ៣២០ គក្រ | មករា ២០០៩ | មេសា ២០០៩ |

## គ-៦ ផែនការថវិកាទ្រទ្រង់សំរាប់អភិវឌ្ឍសហគមន៍

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ប្រជុំផ្សព្វផ្សាយពីការដាក់ពាក្យសុំចូលជាសមាជិក និងប្រមូលប្រាក់ភាគទានសមាជិក | ១/២/២០០៩ | ២/២/២០១០ | ១០០០រ/នាក់ ១៨២.០០០រ | |
| ភាគទានប្រចាំឆ្នាំ | ប្រជុំផ្សព្វផ្សាយស្តីពីការប្រមូលភាគទានប្រចាំឆ្នាំ | ១/២/២០០៩ | ២/៦/២០១០ | ១៨២.០០០រ | |
| ជំនួយសប្បុរសជន និងអង្គការនានា | CCD | | | | |

## គ-៧ ផែនការបង្កើនមុខរបរទ្រទ្រង់ជីវភាពសហគមន៍

| ប្រភេទមុខរបរ | សកម្មភាព និងចំនួន | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|
| ចិញ្ចឹម ត្រី, ជ្រូក, មាន់ | មាន់ ៣ក្បាល/គ្រួសារ (១០គ្រួសារ) ជ្រូក២ក្បាល/គ្រួសារ (១០គ្រួសារ) | ១/៣/ ២០០៩ | ១/៣/ ២០១០ |

| | | | |
|---|---|---|---|
| ដាំបន្លែ ( ននោង, សណ្តែកគួ, ស្ពៃខៀវ, ស្ពៃចង្កឹះ...) | ២០ គ្រួសារ | ១/៦/២០០៩ | ១/៦/២០១០ |
| បណ្តុះផ្សិត | ១គ្រួសារ/២រង ( ២០គ្រួសារ) | ១/៤/២០០៩ | ១/៥/២០១០ |

## គ-៨ ផែនការបោះបង្គោលព្រំប្រទល់សហគមន៍

| ចំនួនបង្គោល | ចំណុចត្រូវបោះ | អ្នកទទួលខុសត្រូវ | ពេលវេលា | | ផ្សេងៗ |
|---|---|---|---|---|---|
| | | | ចាប់ផ្តើម | បញ្ចប់ | |
| ១៤ បង្គោល | តាមចំណុចដែលបានកំនត់ក្នុងផែនទីសហគមន៍ | គណៈកម្មការសហគមន៍នេសាទ | កុម្ភៈ ២០០៩ | មិនា ២០១០ | ត្រូវការជំនួយ និងការសហការពី ស្ថាប័នជំនាញនិងអង្គការនានា |

## គ-៩ ផែនការផ្សព្វផ្សាយ និងលើកកំពស់ការយល់ដឹង

| ប្រធានបទ | ក្រុមគោលដៅ | ពេលវេលា | អ្នកទទួលខុសត្រូវ |
|---|---|---|---|
| លក្ខន្តិកៈនិង បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ៣ នៃឆ្នាំនិមួយៗ | និងរដ្ឋបាលជលផល CFC |
| សារៈប្រយោជន៍នៃធនធានធម្មជាតិ និងបរិស្ថាន | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ៥ នៃឆ្នាំនិមួយៗ | និងរដ្ឋបាលជលផល CFC |
| ផែនទីកំណត់ព្រំប្រទល់កន្លែងនេសាទ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ៨ នៃឆ្នាំនិមួយៗ | និងរដ្ឋបាលជលផល CFC |
| ផែនការគ្រប់គ្រងកន្លែងនេសាទ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ១ នៃឆ្នាំនិមួយៗ | និងរដ្ឋបាលជលផល CFC |
| ច្បាប់ជលផល និងច្បាប់ផ្សេងៗទាក់ទងដល់ការគ្រប់គ្រងសហគមន៍នេសាទ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ៥ នៃឆ្នាំនិមួយៗ | និងរដ្ឋបាលជលផល CFC |
| ការគ្រប់គ្រង និងសារៈប្រយោជន៍នៃព្រៃលិចទឹក | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ១ នៃឆ្នាំនិមួយៗ | និងរដ្ឋបាលជលផល CFC |
| ផលប៉ះពាល់ការប្រើប្រាស់ថ្នាំពុលកសិកម្ម និងការប្រើប្រាស់ឧបរណ៍នេសាទល្មើសច្បាប់ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ២ នៃឆ្នាំនិមួយៗ | និងរដ្ឋបាលជលផល CFC |

## គ-១០ ផែនការពង្រឹងសមត្ថភាពសហគមន៍

| ផែនការ | ប្រធានបទ/ជំនាញ | ក្រុមគោលដៅ | ពេលវេលា | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ពង្រឹងស្ថាប័ន និង ការងារគ្រប់គ្រង | ការធ្វើកំណត់ហេតុ និង របាយការណ៍ | គណៈកម្មការស.ន | កុម្ភៈ ២០០៩ | និងរដ្ឋបាលជលផល CFC |
| | របៀបសរសេរខិតរដ្ឋបាល | គណៈកម្មការស.ន | កក្កដា ២០០៩ | និងរដ្ឋបាលជលផល CFC |
| | រៀបចំទុកដាក់ឯកសារសហគមន៍ និងរបៀបកត់ត្រាប្រចាំថ្ងៃ | គណៈកម្មការស.ន | មិថុនា ២០០៩ | និងរដ្ឋបាលជលផល CFC |
| | ការគ្រប់គ្រងថវិកា | គណៈកម្មការស.ន | កុម្ភៈ ២០០៩ | និងរដ្ឋបាលជលផល CFC |
| | ការដោះស្រាយទំនាស់ | គណៈកម្មការស.ន | | និងរដ្ឋបាលជលផល CFC |
| | ការទំនាក់ទំនង និង សរសេរសំណើសុំថវិកា | គណៈកម្មការស.ន | មេសា ២០០៩ | និងរដ្ឋបាលជលផល CFC |
| | រៀបចំបណ្តាញសហគមន៍ | គណៈកម្មការស.ន | សីហា ២០០៩ | និងរដ្ឋបាលជលផល CFC |
| | ទស្សនះកិច្ចសិក្សាផ្លាស់ប្តូរ បទពិសោធន៍ | គណៈកម្មការស.ន | ១ដង/ឆ្នាំ | និងរដ្ឋបាលជលផល CFC |
| បណ្តុះបណ្តាល បច្ចេកទេស | បណ្តុះ និងដាំព្រៃលិចទឹក | សមាជិក និង គណៈកម្មការស.ន | កញ្ញា ២០០៩ | និងរដ្ឋបាលជលផល CFC |
| | ចិញ្ចឹមត្រី និងសត្វ | សមាជិក និង គណៈកម្មការស.ន | កុម្ភៈ ២០០៩ | និងរដ្ឋបាលជលផល CFC |
| | បណ្តុះផ្សិត | សមាជិក និង គណៈកម្មការស.ន | មិនា ២០០៩ | និងរដ្ឋបាលជលផល CFC |

## ឃ. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោម៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការ រួមមាន៖ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ និងសមាជិកសហគមន៍នេសាទដែលមានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ចដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែល

ទាក់ទងនឹងបច្ចេកទេសជលផលដូចជាៈ ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្ស ព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរក ថវិកាទ្រទ្រង់ជាដើម ។

- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រង សហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

# តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ថ្មី រយៈពេល ៣ ឆ្នាំ (២០០៨ ដល់ ២០១០)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | - ផ្សព្វផ្សាយផែនការប្រើប្រាស់ឧបករណ៍នេសាទដល់សមាជិកសហគមន៍ទាំងអស់ និងអ្នកមកពីខាងក្រៅ<br>- ចុះត្រួតពិនិត្យ និងតាមដានជាប្រចាំ | - សមាជិក និងអ្នកមិនមែនជាសមាជិកសហគមន៍ទាំងអស់បានជ្រួតជ្រាបពីផែនការ<br>- ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ថយចុះ នាំឱ្យត្រីមានការកើនឡើង | - ចំណាយលើការផ្សព្វផ្សាយ ១៥០ ដុល្លា<br>- ចំណាយលើការចុះល្បាត ត្រួតពិនិត្យតាមដាន ១៥០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ប្រាក់បដិភាគរបស់សហគមន៍ | ២០០៩ | ២០១០ | |
| ២. ការកែលំអដែននេសាទ | បឹងកន្លែងវាលទំហំ ១០ ហត ១០០ម x ១០០ម | -ជីវភាពកើនឡើង<br>-ជីវភាពសំបូររុងរឿង<br>-រក្សាមេពូជ | ២០០០ ដុល្លា | -អង្គការ<br>-ជំនាញ | មិនា | ឧសភា ២០១០ | |
| ៣. ការកំណត់ និងរៀបចំតំបន់អភិរក្ស | បឹងវាលទំហំ ១០០មx១០០ម | -ជីវភាពកើនឡើង<br>-ជីវភាពសំបូររុងរឿង<br>-រក្សាមេពូជ | ២០០០ ដុល្លា | -អង្គការ<br>-ជំនាញ | ឧសភា ២០០៩ | សីហា ២០១០ | |
| ៤-ផែនការគ្រប់គ្រងព្រៃលិចទឹក | - ដាំព្រៃលិចទឹកទំហំ ២ ហត រាំង.ត្រស់ | - រក្សាមេពូជត្រី<br>- សំបូរសត្វស្លាប និងធនធានជលផល។<br>- ជីវភាពប្រជាជនកើនឡើង | ៣០០ ដុល្លា | | មិនា ២០០៩ | មេសា ២០១០ | |
| ៥- ផែនការអភិវឌ្ឍ | ចិញ្ចឹមត្រី ២ស្រះ | -ជីវភាពប្រជាជនកើនឡើង | ១០០ ដុល្លា | - សប្បុរសជន | មករា | មេសា | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| នីវារីវប្បកម្ម | ១០ម × ១០ម ចំនួន ៣២០ គក្រ. អណ្តែង | -បង្កើនជីវភាពគ្រួសារ | | - អង្គការ និង ជំនាញ | ២០០៩ | ២០១០ | |
| ៦- ផែនការរកប្រាក់ចំណូលសហគមន៍ | | | | | | | |
| ៧- ផែនការបង្កើនមុខរបរ ទ្រទ្រង់ជីវភាព | - វិភាគ និងចាត់អាទិភាពជំរើសមុខរបរចិញ្ចឹមជីវិត<br>- ស្វែងរកអង្គការ ស្ថាប័នគាំទ្រ<br>- រៀបចំសំណើសុំថវិកា | - ជំរើសមុខរបរចិញ្ចឹមជីវិតត្រូវបានកំនត់ និងចាត់អាទិភាព សំណើសុំថវិកាត្រូវបានរៀបចំ និងទទួលបានការគាំទ្រពីអង្គការនានា | - ចំណាយសរុប ៥០០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | ២០០៩ | ២០១០ | |
| ៨- ផែនការបោះបង្គោល ព្រំប្រទល់សហគមន៍ | សហការជាមួយជំនាញផែនទីកំនត់ទីតាំងត្រូវបោះបង្គោល<br>- ស្វែងរកថវិកាគាំទ្រ | បង្គោលត្រូវបានបោះត្រឹមត្រូវតាមចំនុចដែលកំនត់លើផែនទី ស.នមានព្រំប្រទល់ច្បាស់លាស់កាត់បន្ថយជម្លោះ | - ចំណាយសរុប ៣០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | កុម្ភៈ ២០០៩ | មិនា ២០១០ | |
| ៩- ផែនការផ្សព្វផ្សាយ និងបង្កើនការយល់ដឹង | - ផ្សព្វផ្សាយឱ្យស.គបានយល់ដឹងពី លក្ខន្តិកៈ | ស.គបានយល់ដឹង និងអនុវត្តតាម | - ១០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា | មករា ២០០៩ | ធ្នូ ២០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | បទបញ្ជាផ្ទៃក្នុង ច្បាប់ និងលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធ និងស.ន | | | - ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | | | |
| ១០- ផែនការពង្រឹងសមត្ថភាពសហគមន៍ | - បង្កើនសមត្ថភាពស.គទាំងជំនាញ គ្រប់គ្រងស្ថាប័ន និងបច្ចេកទេស | ស.គចេះជំនាញផ្សេងៗទាក់ទិន និងការងារគ្រប់គ្រងស្ថាប័ន និងបច្ចេកទេស | - ១០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | មករា ២០០៨ | ធ្នូ ២០០៨ | |

## តារាងកម្មវិធីការងារ

| សកម្មភាព | ឆ្នាំ ២០០៨ | | | | | | | | | | | | ឆ្នាំ ២០០៩ | | | | | | | | | | | | ឆ្នាំ ២០១០ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 |
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ២. ការកែលំអដែននេសាទ | | | | | | | | | | | | | | | ■ | ■ | ■ | | | | | | | | | | | | | | | | | | |
| ៣. ការកំណត់ និង រៀបចំតំបន់អភិរក្ស | | | | | | | | | | | | | | | | | | ■ | ■ | ■ | ■ | | | | | | | | | | | | | | |
| ៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | | | | | | | | | | | | ■ | ■ | ■ | | | | | | | | | | | | | | | | | | |
| ៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្មតាមស្រះ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧. ផែនការបង្កើនមុខរបរទ្រទ្រង់ជីវភាព | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៨. ផែនការបោះបង្គោលព្រំប្រទល់ស.គ | | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៩. ផែនការផ្សព្វផ្សាយនិងបង្កើនការយល់ដឹង | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ១០. ផែនការពង្រឹងសមត្ថភាពសហគមន៍ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | |

បានឃើញ និងបញ្ជូនមក

លោកនាយសង្កាត់រដ្ឋបាលជលផល

**នាយសង្កាត់រដ្ឋបាលជលផល**.........

...........ថ្ងៃទី....18....ខែ....09....ឆ្នាំ ២០០8

លេខ :..................

**បានឃើញ**

**មេឃុំ**.........

...............ថ្ងៃទី....18....ខែ....09....ឆ្នាំ ២០០8

លេខ :....421....

...........ថ្ងៃទី....11....ខែ....09..........ឆ្នាំ ២០០8

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

លេខ :....028....

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី...........ខែ.............ឆ្នាំ ២០០

**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

បានឃើញ និងបញ្ជូនមក

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

" ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ "

...........ថ្ងៃទី....27....ខែ....11....ឆ្នាំ ២០០ 8

**នាយអធិការដ្ឋានរដ្ឋបាលជលផល**.........

បានឃើញ និងបញ្ជូនមក

លោកនាយអធិការដ្ឋានរដ្ឋបាលជលផល.........

...........ថ្ងៃទី....21....ខែ....10....ឆ្នាំ ២០០8

**នាយខណ្ឌរដ្ឋបាលជលផល**.........